# مدرسة اهل البيت

# សាលា
# អាស្វ់លុល-បៃត៍

## សៀវភៅ ហ្វីក្ហោះហ្វ៍ ថ្នាក់ទី ៣ (អាយុ ៧-៨ ឆ្នាំ)

រ៉ស្វ៉លុលឡោះហ្វ៍ﷺមានព្រះវចនៈថា៖ "ការស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ - ការមានអស់ឡោះប៉ូ ........ ៣
មេរៀនទី ២ - វ៉ាយ៉ិប ........ ៦
មេរៀនទី ៣ - ហ៊ារ៉ាំ ........ ៨
មេរៀនទី ៤ - មុសតាហ៊ាប់ ........ ១១
មេរៀនទី ៥ - ម៉ាក់រ៉ុះហ្ង៉ ........ ១៤
មេរៀនទី ៦ - មូបាស៊ុ ........ ១៧
មេរៀនទី ៧ - អាស្មាន ........ ១៩
មេរៀនទី ៨ - អាស្មាន (ត) ........ ២២
មេរៀនទី ៩ - អាស្មាន (ត២) ........ ២៤
មេរៀនទី ១០ - អាស្មាន (ត៣) ........ ២៧
មេរៀនទី ១១ - អ៊ីក៏ម៉ាស ........ ៣០
មេរៀនទី ១២ - អាស្មាន និង អ៊ីក៏ម៉ាស៊ុ (សាឡើងវិញ) ........ ៣៤
មេរៀនទី ១៣ - ស៊ូឡាត់ ចំនួនរ៉ក់អាស៊ុ និងពេល ........ ៣៦
មេរៀនទី ១៤ - សូត្រក្នុងស៊ូឡាត់ ........ ៤០
មេរៀនទី ១៥ - សូត្រក្នុងស៊ូឡាត់ ........ ៤៤
មេរៀនទី ១៦ - សូត្រក្នុងស៊ូឡាត់ ........ ៤៧
មេរៀនទី ១៧ - សូត្រក្នុងស៊ូឡាត់ ........ ៥០
មេរៀនទី ១៨ - សូត្រក្នុងស៊ូឡាត់ ........ ៥៣
មេរៀនទី ១៩ - សាឡើងវិញ - សូត្រក្នុងស៊ូឡាត់ ........ ៥៦

**មេរៀនទី ១**

# ការមានអស់ឡោះហ្វ៍

កាលពីព្រេងនាយ មានក្សត្រមួយអង្គប្រកបដោយសីលធម៌គ្រងរាជ្យលើនគរមួយ ។ ប្រជារាស្ត្រនគរនោះមួយចំនួនជឿអស់ឡោះហ្វ៍ មួយចំនួនទៀតពុំមានជំនឿទេ ។

ដើម្បីបញ្ចប់ការឈ្លោះប្រកែកគ្នា ក្សត្រប្រកបដោយសីលធម៌បានចាត់ចែងឲ្យមានការប្រជុំ ពិភាក្សាតទល់មួយរវាងអ្នកមានជំនឿនិងអ្នកឥតជំនឿ ។

លុះដល់ថ្ងៃប្រជុំ តំណាងភាគីឥតជំនឿបានមកដល់រាជវាំង តែព្រឹទ្ធាចារ្យមេដឹកនាំអ្នកមានជំនឿអវត្តមាន ។

គេបានរង់ចាំយ៉ាងយូរ តែពុំមានដំណឹងពីព្រឹទ្ធាចារ្យរូបនោះទេ ។ ពួកឥតជំនឿគិតថាលោកច្បាស់ជាមិនមកទេ ព្រោះតែពុំមានពាក្យឆ្លើយដោះសាជំនឿរបស់លោក ។

ទីបំផុត ព្រឹទ្ធាចារ្យបានមកដល់ ។ គេចង់ដឹងថាហេតុអ្វីលោកមកយឺតពេលម្ល៉េះ ។ ស្តេចបានសូមឲ្យលោកអធិប្បាយអំពីការមកយឺតពេលរបស់លោក ។

ព្រឹទ្ធាចារ្យបានថាលោកបានចេញពីផ្ទះទាន់ពេលវេលា តែដោយហេតុតែលោកត្រូវឆ្លងស្ទឹង លោកពុំមានទូកជិះឆ្លងទេ ។

គេបានស្តាប់លោកអធិប្បាយដោយយកចិត្តទុកដាក់ លោកក៏បានអធិប្បាយ

បន្តទៀត ។

បន្ទាប់មក លោកបានថាពេលដែលលោកកំពុងរង់ចាំទូកចម្លងនោះ លោកបានឃើញក្តារផុសចេញពីក្នុងទឹកមកតភ្ជាប់គ្នាដោយដែកគោល លុះកើតជាទូកមួយ ។

ការសាងសង់ឡើងដោយឯកឯងនេះប្រើពេលយូរបន្តិច ហើយនេះជាមូលហេតុដែលធ្វើឲ្យលោកមកយឺតពេល ។

ពួកឥតជំនឿក្រេវក្រោធហើយបានថាព្រឹទ្ធាចារ្យនិយាយកុហក ។ ព្រឹទ្ធាចារ្យបានសួរថាហេតុអ្វីពួកគេមិនព្រមជឿរឿងទូក ដែលសាងឡើងដោយឯកឯងនោះ ឯពួកគេវិញចង់ឲ្យមនុស្សម្នាជឿថាលោកនេះនិងអ្វីៗដែលមាននៅក្នុងនោះបានកើតឡើងដោយឯកឯង ហើយខ្លួនពួកគេផ្ទាល់ក៏មិនជឿថាអល់ឡោះហ្វជាព្រះអ្នកបង្កើតអ្វីៗសព្វគ្រប់នោះទេ ។

ពុំមានអ្នកឥតជំនឿណាម្នាក់ឆ្លើយព្រឹទ្ធាចារ្យរួចទេ ។ នៅទីបំផុតភាគីអ្នកមានជំនឿបានឈ្នះគេ ។

# កិច្ចការសិស្ស ១

ចូរគូររឿងរ៉ាវបន្ទះក្តារនិងដែកគោលដែលបានផុសឡើងពីក្នុងទឹក ដែលលោកព្រឹទ្ធាចារ្យបានតំណាល ។

តើលោកព្រឹទ្ធាចារ្យចង់បង្ហាត់បង្រៀនពួកឥតជំនឿនូវមេរៀនអ្វី ដោយប្រឌិតឡើងនូវរឿងនេះ ?

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

_________________________________

**មេរៀនទី ២**

# វ៉ាយ៉ិប

អ្វីមួយជាវ៉ាយ៉ិប បានសេចក្តីថាអ្នកត្រូវតែធ្វើអ្វីមួយនោះជាចាំបាច់ ។ អ្នកមិនមានជំរើសទេ ។

នេះគឺអ្វីមួយដែលអល់ឡោះហ៍្វបានប្រាប់ឲ្យអ្នកធ្វើ ។ ដូច្នេះបើអ្នកមិនធ្វើទេ អ្នកនឹងប្រព្រឹត្តដូចស្ទៃត្ទនដែលមិនបានស្តាប់បង្គាប់អល់ឡោះហ៍្វ ។

ព្រោះតែព្រះអង្គបានបង្កើតអ្នកមក បានជាព្រះទ្រង់ញាណច្បាស់ថាអ្វីខ្លះល្អសម្រាប់អ្នក ។

បើអ្នកមិនធ្វើអ្វីមួយដែលវ៉ាយ៉ិបទេនោះ អ្នកមិនធ្វើឲ្យអល់ឡោះហ៍្វខូចខាតទេ តែខ្លួនអ្នកទេដែលខូចខាត ។

ការប្រាប់ឲ្យអ្នកធ្វើអ្វីមួយនោះ មិននាំមកនូវផលប្រយោជន៍និងសេចក្តីវិនាសដល់អល់ឡោះហ៍្វទេ ។ ព្រះអង្គមិនត្រូវការអ្វីនិងមិនត្រូវការអ្នកណាឡើយ ។

អល់ឡោះហ៍្វស្រឡាញ់យើងណាស់ ព្រះអង្គបីបាច់រក្សាយើង ។ ដូច្នេះហើយបានជាព្រះអង្គឲ្យអ្វីមួយវ៉ាយ៉ិបដើម្បីនឹងប្រាកដថាយើងនឹងធ្វើអ្វីនោះ ។

ពេលណាយើងធ្វើអ្វីមួយដែលវ៉ាយ៉ិប ពេលនោះអល់ឡោះហ៍្វឲ្យរង្វាន់យើង ។ បើយើងមិនធ្វើអ្វីដែលវាយ៉ិបនោះទេ អល់ឡោះហ៍្វនឹងឲ្យអ៊ាស្សាបយើង (គឺធ្វើទោសយើង) ។

**ចូរចងចាំថា វ៉ាយ៉ិបមានសេចក្តីថាត្រូវធ្វើ (ចាំបាច់)**!

# កិច្ចការសិស្ស ២

នៅខាងក្រោមនេះគឺអ្វីដែលវ៉ាឃ្យិប ។ ចូរផាត់ព័ណ៌និងសាកគូរអ្វីផ្សេងទៀតដែលជាវ៉ាឃ្យិបដែរ ។








ចូរគូសគំនូសចំណាំធំមួយ (✓) នៅខាងលើទំព័រនេះ ពីព្រោះវ៉ាឃ្យិបមានសេចក្ដីថាអ្នកត្រូវតែធ្វើ ។

**មេរៀនទី ៣**

# ហ្រាំ

អ្វីមួយដែលហ្រាំ (حَرَام) មានសេចក្តីថាអ្នកមិនត្រូវធ្វើអ្វីមួយនោះជាដាច់ខាត ។ អ្នកមិនមានជម្រើសទេ ។

នេះគឺអ្វីមួយដែលអល់ឡោះហ្វ៍ប្រាប់មិនឲ្យអ្នកធ្វើវាទេ ។

អល់ឡោះហ្វ៍ហាមអ្នកតែអ្វីមួយដែលមិនល្អសម្រាប់អ្នកទេ ។ ព្រោះតែព្រះអង្គបានបង្កើតអ្នកមកបានជាព្រះអង្គទ្រង់ញាណច្បាស់ថាអ្វីខ្លះល្អសម្រាប់អ្នក អ្វីខ្លះមិនល្អសម្រាប់អ្នក ។

បើអ្នកធ្វើអ្វីមួយដែលហ្រាំសម្រាប់អ្នក អ្នកមិនធ្វើឲ្យអល់ឡោះហ្វ៍ខូចខាតទេ តែអ្នកធ្វើឲ្យខ្លួនឯងខូចខាតវិញទេ ។

ការហាមប្រាមអ្នកមិនឲ្យធ្វើអ្វីមួយ មិនធ្វើឲ្យអល់ឡោះហ្វ៍បានចំណេញនិងខាតដើមទេ ។ ព្រះអង្គក៏មិនសព្វព្រះហឫទ័យថា **ទេ**! ទេដែរ ។ ព្រះអង្គមិនត្រូវការអ្វីនិងមិនត្រូវការអ្នកណាមួយឡើយ ។

អល់ឡោះហ្វ៍ទ្រង់ស្រឡាញ់យើងណាស់ ព្រះអង្គបីបាច់រក្សាយើង ។ ដូច្នេះហើយបានជាព្រះអង្គធ្វើឲ្យអ្វីមួយហ្រាំសម្រាប់យើង ដើម្បីនឹងប្រាកដថាយើងនឹងមិនធ្វើវាទេ ។

កាលណាយើងចៀសវាងអ្វីមួយដែលហ្រាំ កាលនោះអល់ឡោះហ្វ៍ទ្រង់ប្រទាន

ឲ្យយើងនូវរង្វាន់ (ស្ញ្រាវ៉ាប)។ បើយើងរឹងទទឹង ចចេសធ្វើអ្វីដែលហ្វ្រាពុំអល់ឡោះហ្វ៍នឹងឲ្យទោសយើង (អ៊ុស្វ៊ាប)។

**ចូរអ្នកចងចាំថា ហ្វ្រាពុំមានសេចក្ដីថា អ្នកមិនត្រូវធ្វើជាដាច់ខាត**!

# កិច្ចការសិស្ស ៣

រូបខាងនេះជាតំណាងអ្វីដែលសុទ្ធតែហ្វារ៉ាំ ។ ចូរផាត់ព័ណ៌លើរូបទាំងនេះ ហើយចូរគូររូបឯ ទៀតដែលតាងអ្វីដែលហ្វារ៉ាំដែរ ។







ចូរគូសខ្វែង (×) ធំមួយនៅខាងលើទំព័រនេះ ពីព្រោះហ្វារ៉ាំមានសេចក្តីថាយើងមិនត្រូវធ្វើជាដាច់ខាត ។

**មេរៀនទី ៤**

# មុសតាហ្ហាប់

អ្វីមួយដែលមុសតាហ្ហាប់ (مستحب) មានសេចក្ដីថាអ្នកគប្បីព្យាយាមធ្វើអ្វីមួយនោះ ។ អ្នកមានជម្រើស ។ បើអ្នកមិនធ្វើអ្វីនោះទេ ពុំមានទោសទេ តែជាការប្រសើរសម្រាប់អ្នកបើអ្នកធ្វើ ។

អល់ឡោះហ្វ៍ឲ្យអ្នកធ្វើតែអ្វីមួយដែលប្រសើរសម្រាប់អ្នក ។ ព្រោះតែព្រះអង្គជាអ្នកបង្កើតអ្នក បានជាព្រះអង្គទ្រង់ញាណថាអ្វីខ្លះប្រសើរសម្រាប់អ្នក ។

អល់ឡោះហ្វ៍បានធ្វើឲ្យអ្វីមួយមុសតាហ្ហាប់ ព្រោះវាប្រសើរសម្រាប់យើង បើយើងធ្វើអ្វីនោះ ។

បើអ្នកមិនធ្វើអ្វីមួយដែលមុសតាហ្ហាប់ទេ អ្នកមិនធ្វើអាក្រក់ទេ (ពុំនោះទេវាជាវ៉ាយ៉ិប) ។

ឲ្យអ្នកធ្វើអ្វីមួយ ឬមិនឲ្យអ្នកធ្វើអ្វីមួយ មិននាំមកឲ្យអល់ឡោះហ្វ៍នូវអ្វីមួយឡើយ ព្រះអង្គមិនត្រូវការអ្វីមួយឡើយនិងមិនត្រូវការអ្នកណាមួយឡើយ ។

អល់ឡោះហ្វ៍ទ្រង់សព្វព្រះហឫទ័យយើង ព្រះអង្គបីបាច់រក្សាយើង ។ ដូច្នេះហើយបានជាព្រះអង្គឲ្យអ្វីមួយទៅជាមុសតាហ្ហាប់សម្រាប់យើង ដើម្បីនឹងឲ្យយើងមានឱកាសកសាងខ្លួនឲ្យបានល្អប្រសើរទ្វេឡើង ។

បើយើងធ្វើអ្វីមួយដែលមុសតាហ្ហាប់ អល់ឡោះហ្វ៍ឲ្យរង្វាន់យើង (ស្វាវ៉ាប) ។ បើ

យើងមិនធ្វើទេ យើងនឹងមិនបានរង្វាន់ (ស្នារ៉ាប) ទេ ហើយក៏នឹងមិនមានទោស (អ៊ុស្សាប់) ទេដែរ ។

**ចូរអ្នកចងចាំថា មុសតាហ៊ាប់មានសេចក្ដីថា យើងគប្បីព្យាយាមធ្វើ!**

# កិច្ចការសិស្ស ៤

រូបខាងក្រោមនេះសុទ្ធតែអ្វីដែលមុសតាហ្វាប់ ។ ចូរផាត់ព័ណ៌លើរូបទាំងនេះ ហើយគូររូបឯទៀតដែលមុសតាហ្វាប់ដែរ ។







ចូរគូសគំនូសចំណាំតូចមួយ (✓) នៅខាងលើទំព័រនេះ ពីព្រោះមុសតាហ្វាប់មានសេចក្តីថាអ្នកគប្បីព្យាយាមធ្វើ ។

**មេរៀនទី ៥**

# ម៉ាក់រុះហ្វ៍

អ្វីមួយដែលម៉ាក់រុះហ្វ៍ (مكروه) មានសេចក្ដីថាអ្នកគប្បីព្យាយាមចៀសវាងអ្វីនោះ ។ អ្នកមានជម្រើស ។ បើអ្នកធ្វើអ្វីនោះ ពុំមានទោសទេ ។ តែបើអ្នកមិនធ្វើអ្វីនោះទេ ជាការប្រសើរបំផុតសម្រាប់អ្នក ។

អល់ឡោះហ្វ៍ឲ្យអ្នកចៀសវាងតែអ្វីដែលមិនល្អប្រសើរសម្រាប់អ្នកទេ ។ ព្រោះតែព្រះអង្គជាអ្នកបង្កើតអ្នក បានជាព្រះអង្គទ្រង់ញាណអ្វីដែលល្អប្រសើរសម្រាប់អ្នក ។

អល់ឡោះហ្វ៍បានធ្វើឲ្យអ្វីមួយជាម៉ាក់រុះហ្វ៍សម្រាប់អ្នក ព្រោះវាជាការល្អប្រសើរសម្រាប់អ្នក បើអ្នកមិនធ្វើអ្វីនោះទេ ។

ប្រសិនបើអ្នកធ្វើអ្វីមួយដែលម៉ាក់រុះហ្វ៍ អ្នកមិនបានធ្វើបាបទេ (ពុំនោះទេវាជាហ្ការ៉ាំ) ។

មិនឲ្យអ្នកធ្វើអ្វីមួយ មិននាំមកឲ្យអល់ឡោះហ្វ៍នូវផលប្រយោជន៍ឬផលវិបត្តិឡើយ ។ ព្រះអង្គមិនត្រូវការអ្វីមួយនិងអ្នកណាមួយឡើយ ។

អល់ឡោះហ្វ៍ទ្រង់សព្វព្រះហឫទ័យយើងណាស់ ព្រះអង្គបីបាច់រក្សាយើង ។ ដូច្នេះហើយបានជាព្រះអង្គធ្វើឲ្យអ្វីមួយជាម៉ាក់រុះហ្វ៍ ដើម្បីនឹងឲ្យយើងមានឱកាសកសាងខ្លួនឲ្យបានល្អប្រសើរទ្វេឡើង ។

បណ្តាព្រះសាស្តាយើងនិងបណ្តាអ៊ីម៉ាំយើងមិនធ្វើអ្វីមួយដែលហ៊ារ៉ាំ ឬម៉ាក់រ៊ុះហ៍ទេ ។ យើងគប្បីយកគំរូតាមព្រះអង្គ ។

បើយើងចៀសវាងធ្វើអ្វីមួយដែលម៉ាក់រ៊ុះហ៍ អល់ឡោះហ៍ឲ្យរង្វាន់យើង (ស្ញាវ៉ាប) ។ បើយើងធ្វើ យើងនឹងមិនបានរង្វាន់ (ស្ញាវ៉ាប) ទេ ហើយក៏នឹងមិនមានទោស (អ៊ិកស្ញាប់) ទេដែរ ។

**ចូរអ្នកចងចាំថា ម៉ាក់រ៊ុះហ៍មានសេចក្តីថា យើងគប្បីព្យាយាមចៀសវាងធ្វើ!**

# កិច្ចការសិស្ស ៥

រូបខាងក្រោមនេះសុទ្ធតែតាងអ្វីដែលម៉ាក់រុះហ្វ៍ ។ ចូរផាត់ព័ណ៌លើរូបទាំងនេះ ហើយគូររូបឯ ទៀតដែលតាងអ្វីដែលម៉ាក់រុះហ្វ៍ដែរ ។



ចូរគូសខ្វែង (×) តូចមួយនៅខាងលើទំព័រនេះ ពីព្រោះម៉ាក់រុះហ្វ៍មានសេចក្ដីថា យើងព្យាយាមចៀសវាងធ្វើ ។

**មេរៀនទី ៦**

# ម្ហបាស៊្

អ្វីមួយដែលម្ហបាស៊្ (مباح) មានសេចក្តីថាអនុញ្ញាតឲ្យធ្វើអ្វីនោះដោយគ្មានសេចក្តីបញ្ជាក់ច្បាស់លាស់ ។ អ្នកអាចធ្វើឬមិនធ្វើអ្វីនោះស្រេចតែលើអ្នក ។

នោះគឺអ្វីដែលអល់ឡោះហ្ទ័មិនធ្វើឲ្យទៅជាល្អ តែក៏មិនធ្វើឲ្យទៅជាអាក្រក់ទេដែរសម្រាប់អ្នក ។ ព្រោះតែព្រះអង្គបានបង្កើតអ្នកមកបានជាព្រះអង្គទ្រង់ញាណច្បាស់ថាអ្វីមួយល្អប្រសើរឬមិនល្អប្រសើរសម្រាប់អ្នក ។

បើអ្នកធ្វើអ្វីមួយដែលម្ហបាស៊្ អ្នកមិនបានធ្វើល្អទេ តែក៏មិនបានធ្វើអាក្រក់ទេដែរ (ពុំនោះទេ វាជាវ៉ាយិុប ឬ ហ្ចារ៉ាំ) ។

អល់ឡោះហ្ទ័ទ្រង់សព្វព្រះហឫទ័យយើងណាស់ ព្រះអង្គបីបាច់រក្សាយើង ។ ដូច្នេះហើយបានជា ទោះបីយើងធ្វើអ្វីមួយដែលម្ហបាស៊្ក៏ដោយ ក៏ព្រះអង្គទុកឱកាសឲ្យយើងទទួលបាននូវរង្វាន់ (ស្ហ្ញវ៉ាប់) ដែរ ។ យើងគ្រាន់តែប្រាកដក្នុងចិត្តថាយើងធ្វើអ្វីដែលម្ហបាស៊្នោះដើម្បីអល់ឡោះហ្ទ័ ។ យើងជាមុស្លីម ដូច្នេះ អ្វីៗដែលយើងធ្វើ យើងត្រូវធ្វើដើម្បីសព្វព្រះហឫទ័យអល់ឡោះហ្ទ័ (ឧទាហរណ៍ យើងគប្បីសូត្រ "ប៊ិសមិលឡាស្ហ៍" មុនទទួលទាន) ។

បើអ្នកធ្វើអ្វីមួយដែលម្ហបាស៊្ អ្នកមិនបានរង្វាន់ (ស្ហ្ញវ៉ាប់) ទេ ហើយក៏មិនមានទោសទេដែរ (អ៊្ហស្ហាប់) វៀរលែងនៀត (គោលបំណង) របស់អ្នកគឺ "លិលឡាស្ហ៍" (ដើម្បីអល់ឡោះហ្ទ័) ។

**ចូរអ្នកចងចាំថា ម្ហបាស៊្មានសេចក្តីថា "ទង្វើសេរី" ស្រេចតែលើអ្នក!**

# កិច្ចការសិស្ស ៦

រូបខាងក្រោមនេះសុទ្ធតែតាងអ្វីដែលមួបាស្ង់ ។ ចូរផាត់ព័ណ៌លើរូបទាំងនេះ ហើយគូររូបឯទៀតដែលតាងអ្វីដែលមួបាស្ង់ដែរ ។










ចូរសរសេរនៀតរបស់អ្នកត្រង់ទង្វើនីមួយៗខាងលើនេះ និងត្រង់ទង្វើដែលអ្នកបានគូរផងដែរ ។

**មេរៀនទី ៧**

# អាស្ហាន

អាស្ហាន (أذان) គឺការប្រកាសហៅឲ្យមកធ្វើនមស្ការបូជាអល់ឡោះហ្វ៍ (ស្ហ៍ឡាត្ហ៍) ។ ពេលណា គេឮអាស្ហាន ពេលនោះគេដឹងថាដល់ពេលធ្វើនមស្ការបូជាអល់ឡោះហ្វ៍ហើយ ។

មានស្ហ៍ឡាត្ហ៍ប្រាំជាស្ហ៍ឡាត្ហ៍វ៉ាឃ្ជិប ។ យើងត្រូវតែធ្វើស្ហ៍ឡាត្ហ៍ទាំងនោះ ។ ស្ហ៍ឡាត្ហ៍នីមួយៗ ក្នុងចំណោមស្ហ៍ឡាត្ហ៍ទាំងប្រាំនោះ មានពេលពិសេសសម្រាប់ធ្វើ ។

អាស្ហានបញ្ជាក់ប្រាប់គ្រប់គ្នាថា ពេលពិសេសសម្រាប់ស្ហ៍ឡាត្ហ៍នោះបានមកដល់ហើយ ។

អល់ឡោះហ្វ៍ទ្រង់សព្វព្រះហឫទ័យ ឲ្យយើងសូត្រអាស្ហានមុនចាប់ផ្ដើមធ្វើស្ហ៍ឡាត្ហ៍ ទោះបីមិនមែននៅពេលពិសេសក៏ដោយ ។

នៅពេលដែលអ្នកកើតមក គេសូត្រអាស្ហានដាក់ត្រចៀកស្ដាំអ្នក (និងអ៊ីក្ហ៍ម៉ាស្ហ៍ (إقامة) ដាក់ត្រចៀកឆ្វេងអ្នក) ។

ពេលណាគេកំពុងតែសូត្រអាស្ហាន ពេលនោះអ្នកត្រូវសូត្រតាមតិចៗតាមក្រោយអ្នកសូត្រ (មូអ៊ីស្ហ៊ីន مؤذّن) ។

អ្វីដែលគេថាក្នុងអាស្ហាន (បន្ទាប់ពី "ប៊ិសមិលឡាស្ហ៍") គឺ៖

# اَللّٰهُ اَكْبَرُ

មានន័យថា៖ អល់ឡោះហ្វ៍ធំធ្មើងបំផុត ។

ថាដូចនេះប្អូនដង ។

## កិច្ចការសិស្ស ៧




ចូរគូរនៅខាងក្រោមនេះ នូវពេលដែលអ្នកគិតថាជាពេលសូត្រអាស្មានខ្លាំងៗ

**មេរៀនទី ៨**

# អាសាន (ត)

បន្ទាប់ពីបានថា៖

اَللّٰهُ اَكْبَرُ ៤ ដងហើយ

អ្នកត្រូវថា៖

اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ

មានន័យថា៖ ខ្ញុំសូមប្តេជ្ញាថាមិនមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ ។
ឲ្យថាពីរដង ។

បន្ទាប់មក អ្នកត្រូវថា៖

اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ

មានន័យថា៖ ខ្ញុំសូមប្តេជ្ញាថា មូហាំម៉ាដ់ជាព្រះសាស្តារបស់អល់ឡោះហ្វ៍ ។
ឲ្យថាពីរដង តែក្រោយពីបានថាហើយរៀងរាល់ដង អ្នកត្រូវសូត្រស្វ៉ឡាវ៉ាត ព្រោះអ្នកបានថាព្រះនាមរបស់ព្រះសាស្តា ﷺ ។

បន្ទាប់មក អ្នកត្រូវថា៖

اَشْهَدُ اَنَّ عَلِيًّ وَّلِيُّ اللّٰهُ

មានន័យថា៖ ខ្ញុំសូមប្តេជ្ញាថាអាលីជាទីស្រឡាញ់របស់អល់ឡោះហ្វ៍ ។
ឲ្យថាពីរដង តែក្រោយពីបានថាហើយរៀងរាល់ដង អ្នកត្រូវសូត្រស្វ៉ឡាវ៉ាត ព្រោះអ្នកបាន ថាព្រះនាមរបស់អ៊ីម៉ាំទី ១ صلوات الله عليه والسلام ។

## កិច្ចការសិស្ស ៨

ចូរទន្ទេញបីឃ្លានេះឲ្យចាំ ។

اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ - ២ ដង

اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ - ២ ដង

اَشْهَدُ اَنَّ عَلِيًّ وَّلِيُّ اللّٰهُ - ២ ដង



ចូរសរសេរន័យរបស់បីឃ្លានេះនៅលើបន្ទាត់ខាងក្រោមនេះ

___

___

___

**មេរៀនទី ៩**

# អាស្សាន (ត២)

បន្ទាប់ពីបានថា៖

اَللّٰهُ اَكْبَرُ ៤ ដង

اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ - ២ ដង

اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ - ២ ដង

اَشْهَدُ اَنَّ عَلِيًّ وَّلِيُّ اللّٰهُ - ២ ដង

អ្នកត្រូវថា៖

حَيَّ عَلَى الصَّلَاةِ

មានន័យថា៖ ចូរអ្នកប្រញាប់មកបំពេញស្ហឡាត់ ។
ឲ្យសូត្រ ២ ដង ។

បន្ទាប់មក អ្នកត្រូវថា៖

حَيَّ عَلَى الْفَلَاحِ

មានន័យថា៖ ចូរអ្នកប្រញាប់ឆ្ពោះទៅរកជោគជ័យ ។
ឲ្យសូត្រ ២ ដង ។

បន្ទាប់មក អ្នកត្រូវថា៖

حَيَّ عَلَى خَيْرِ الْعَمَلِ

មានន័យថា៖ ចូរអ្នកប្រញាប់ឆ្ពោះទៅរកទង្វើដ៏ល្អបំផុត ។

ឲ្យសូត្រ ២ ដង ។

# កិច្ចការសិស្ស ៩

ចូរទន្ទេញបីឃ្លានេះឲ្យចាំ ។

حَيَّ عَلَى الصَّلَاةِ - ២ ដង

حَيَّ عَلَى الْفَلَاحِ - ២ ដង

حَيَّ عَلَى خَيْرِ الْعَمَلِ - ២ ដង



ចូរសរសេរន័យរបស់បីឃ្លានេះនៅលើបន្ទាត់ខាងក្រោមនេះ

________________________________________

________________________________________

________________________________________

**មេរៀនទី ១០**

# អាស្ហ៊ាន (ត៣)

ពីរឃ្លាចុងក្រោយរបស់អាស្ហ៊ានគឺ៖

اَللّٰهُ اَكْبَرُ

មានន័យថា៖ អល់ឡោះហ្ទំធំធ្លើងបំផុត ។

ឲ្យសូត្រ ២ ដង ។

នៅទីបញ្ចប់ អ្នកត្រូវថា៖

لَا اِلٰهَ اِلَّا اللّٰهُ

មានន័យថា៖ មិនមានព្រះផ្សេងពីអល់ឡោះហ្ទ៏ឡើយ ។

ឲ្យថា ២ ដង ។

## កិច្ចការសិស្ស ១០

ចូរទន្ទេញពីរឃ្លានេះឲ្យចាំ ហើយត្រូវថាប៉ុន្មានដង ។




ចូរសរសេរន័យរបស់ពីរឃ្លានេះនៅលើបន្ទាត់ខាងក្រោមនេះ

________________________________________

________________________________________

ចូរអ្នកខឹតខំសូត្រអាស្មានទាំងអស់ (ទំព័រតទៅ) ។

# អាស្សានសរុប

اَللّٰهُ اَكْبَرُ (៤ ដង)

អល់ឡោះហ្វធំធ្មើងបំផុត

اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ (២ ដង)

ខ្ញុំសូមប្តេជ្ញាថាមិនមានព្រះផ្សេងពីអល់ឡោះហ្វទ្បើយ

اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ (២ ដង)

ខ្ញុំសូមប្តេជ្ញាថាមូហាំម៉ាដ្ជជាព្រះសាស្តារបស់អល់ឡោះហ្វ (ស្វ៉ូឡាវ៉ាត)

اَشْهَدُ اَنَّ عَلِيًّ وَّلِيُّ اللّٰهُ (២ ដង)

ខ្ញុំសូមប្តេជ្ញាថាអ៊ុលីជាទីស្រឡាញ់របស់អល់ឡោះហ្វ (ស្វ៉ូឡាវ៉ាត)

حَيَّ عَلَى الصَّلَاةِ (២ ដង)

ចូរអ្នកប្រញាប់មកបំពេញស្វ៉ឡាត្

حَيَّ عَلَى الْفَلَاحِ (២ ដង)

ចូរអ្នកប្រញាប់ឆ្ពោះទៅរកជោគជ័យ ។

حَيَّ عَلَى خَيْرِ الْعَمَلِ (២ ដង)

ចូរអ្នកប្រញាប់ឆ្ពោះទៅរកទង្វើដ៏ល្អបំផុត ។

اَللّٰهُ اَكْبَرُ (២ ដង)

អល់ឡោះហ្វធំធ្មើងបំផុត

لَا اِلٰهَ اِلَّا اللّٰهُ (២ ដង)

មិនមានព្រះផ្សេងពីអល់ឡោះហ្វទ្បើយ ។

**មេរៀនទី ១១**

# អ៊ីក៏្វម៉ាស្ទ៌

អ៊ីក៏្វម៉ាស្ទ៌ (إقامة) គឺការប្រកាសចាប់ផ្តើមធ្វើនមស្ការបូជាអល់ឡោះហ្វ៌ ។ ពេលណាគេឮ អ៊ីក៏្វម៉ាស្ទ៌ ពេលនោះគេដឹងថាស្វ៉ឡាត្ទ៌នឹងចាប់ផ្តើមហើយ ។

អល់ឡោះហ្វ៌ទ្រង់សព្វព្រះហឫទ័យ ឲ្យយើងសូត្រអ៊ីក៏្វម៉ាស្ទ៌មុនចាប់ផ្តើមបំពេញពាល់ស្វ៉ឡាត្ទ៌ ។

ពេលអ្នកកើតមក គេសូត្រអាស្សានដាក់ត្រចៀកស្តាំអ្នករាល់គ្នា អ៊ីក៏្វម៉ាស្ទ៌ដាក់ត្រចៀកឆ្វេងអ្នក ។

បើគេកំពុងតែសូត្រអ៊ីក៏្វម៉ាស្ទ៌ អ្នកត្រូវសូត្រតិចៗតាមគេអ្នកសូត្រ ។

អ៊ីក៏្វម៉ាស្ទ៌ស្រដៀងអាស្សានដែរ តែខុសគ្នាត្រង់បីចំណុចគឺៈ

១) اَللّٰهُ اَكْبَرُ ដំបូង ។ ថាតែ ២ ដង មិនថា ៤ ដង ទេ ។

២) لَا اِلٰهَ اِلَّا اللّٰهُ ចុងក្រោយ ។ ថាតែ ១ ដង មិនថា ២ ដង ទេ ។

៣) ត្រង់ចន្លោះបន្ទាត់ទី ៧ (حَيَّ عَلَى خَيْرِ الْعَمَلِ) និងបន្ទាត់ទី ៨ (اَللّٰهُ اَكْبَرُ) អ្នកត្រូវសូត្រថាៈ

قَدْ قَامَتِ الصَّلَاةِ ២ ដង

មានន័យថាៈ ស្វ៉ឡាត្ទ៌ចាប់ផ្តើមហើយ ។

## កិច្ចការសិស្ស ១១

ចូរទន្ទេញមួយឃ្លាថ្មីដែលនៅក្នុងអ៊ីកំ៉ាម៉ាស់ មិនមាននៅក្នុងអាស្ហានទេ ។




ចូរសរសេរចំណុចខុសគ្នារវាងអ៊ីកំ៉ាម៉ាស់និងអាស្ហាននៅលើបន្ទាត់ខាងក្រោមនេះ ។

______________________________

______________________________

ចូរប្រឹតប្រៀងសូត្រអ៊ីកំ៉ាម៉ាស់ទាំងអស់ (ទំព័រតទៅ) ហើយកត់សម្គាល់ចំណុចខុសគ្នាជាមួយអាស្ហាន ។

# អ៊ីក៏ម៉ាស់សរុប

اَللّٰهُ اَكْبَرُ (២ ដង)

អល់ឡោះហ្វ៍ធំថ្កើងបំផុត

اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ (២ ដង)

ខ្ញុំសូមប្តេជ្ញាថាមិនមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ

اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ (២ ដង)

ខ្ញុំសូមប្តេជ្ញាថាមូហ៊ាំម៉ាដ្ជជាព្រះសាស្តារបស់អល់ឡោះហ្វ៍ (ស្វ៊ឡាវ៉ាត)

اَشْهَدُ اَنَّ عَلِيًّ وَّلِيُّ اللّٰهُ (២ ដង)

ខ្ញុំសូមប្តេជ្ញាថាអ៊ុលីជាទីស្រឡាញ់របស់អល់ឡោះហ្វ៍ (ស្វ៊ឡាវ៉ាត)

حَيَّ عَلَى الصَّلَاةِ (២ ដង)

ចូរអ្នកប្រញាប់មកបំពេញស្វ៊ឡាត្ន

حَيَّ عَلَى الْفَلَاحِ (២ ដង)

ចូរអ្នកប្រញាប់ឆ្ពោះទៅរកជោគជ័យ ។

حَيَّ عَلَى خَيْرِ الْعَمَلِ(២ ដង)

ចូរអ្នកប្រញាប់ឆ្ពោះទៅរកទង្វើដ៏ល្អបំផុត ។

قَدْ قَامَتِ الصَّلَاةِ ២ ដង

ស្វ៊ឡាត្នចាប់ផ្តើមហើយ ។

اَللّٰهُ اَكْبَرُ (២ ដង)

អល់ឡោះហ្វ៍ធំថ្កើងបំផុត

لَا اِلٰهَ اِلَّا اللّٰهُ (១ ដង)

មិនមានព្រះផ្សេងពីអល់ឡោះហ្ញូទ្បើយ ។

**មេរៀនទី ១២**

# អាសុាន និង អ៊ីក្វ៏ម៉ាស្វ់ (សាឡើងវិញ)

| អាសុាន - ប្រកាសឲ្យមកបំពេញស្វ៏ឡាត្ត់ | អ៊ីក្វ៏ម៉ាស្វ់ - ប្រកាសមុនចាប់ផ្ដើមស្វ៏ឡាត្ត់ |
|---|---|
| اَللّٰهُ اَكْبَرُ ៤ ដង | اَللّٰهُ اَكْبَرُ ២ ដង |
| អល់ឡោះហ្វ៏ធំធ្ងើងបំផុត | |
| اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ ២ ដង | اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ ២ ដង |
| ខ្ញុំសូមប្ដេជ្ញាថាមិនមានព្រះផ្សេងពីអល់ឡោះហ្វ៏ឡើយ | |
| اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ ២ ដង | اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ ២ ដង |
| ខ្ញុំសូមប្ដេជ្ញាថាមូហ៊ាំម៉ាដ់ជាព្រះសាស្ដារបស់អល់ឡោះហ្វ៏ (ស្វ៏ឡាវ៉ាត) | |
| اَشْهَدُ اَنَّ عَلِيًّ وَّلِيُّ اللّٰهُ ២ ដង | اَشْهَدُ اَنَّ عَلِيًّ وَّلِيُّ اللّٰهُ ២ ដង |
| ខ្ញុំសូមប្ដេជ្ញាថាអាលីជាទីស្រឡាញ់របស់អល់ឡោះហ្វ៏ (ស្វ៏ឡាវ៉ាត) | |
| حَيَّ عَلَى الصَّلَاةِ ២ ដង | حَيَّ عَلَى الصَّلَاةِ ២ ដង |
| ចូរអ្នកប្រញាប់មកបំពេញស្វ៏ឡាត្ត់ | |
| حَيَّ عَلَى الْفَلَاحِ ២ ដង | حَيَّ عَلَى الْفَلَاحِ ២ ដង |
| ចូរអ្នកប្រញាប់ឆ្ពោះទៅរកជោគជ័យ | |
| حَيَّ عَلَى خَيْرِ الْعَمَلِ ២ ដង | حَيَّ عَلَى خَيْرِ الْعَمَلِ ២ ដង |
| ចូរអ្នកប្រញាប់ឆ្ពោះទៅរកទង្វើដ៏ល្អបំផុត | |
| | قَدْ قَامَتِ الصَّلَاةِ ២ ដង<br>ស្វ៏ឡាត្ត់ចាប់ផ្ដើមហើយ |
| اَللّٰهُ اَكْبَرُ ២ ដង | اَللّٰهُ اَكْبَرُ ២ ដង |

| អល់ឡោះហ្វ៍ធំថ្កើងបំផុត | |
|---|---|
| لَا اِلٰهَ اِلَّا اللّٰهُ ២ ដង | لَا اِلٰهَ اِلَّا اللّٰهُ ១ ដង |
| មិនមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ ។ | |

**មេរៀនទី ១៣**

# ស្វ៉ឡាត់ ចំនួនរ៉ក់អ្ហាត់ និងពេល

មុស្លីមធ្វើបំពេញប្រាំស្វ៉ឡាត់ក្នុងមួយថ្ងៃ ស្វ៉ឡាត់នីមួយត្រូវបែងចែកជារ៉ក់អ្ហាត់ (ركعة) ។

មួយរ៉ក់អ្ហាស់មាន៖ គ្វីយ៉ាម រុគូអ៊ុ គ្វីយ៉ាម សាច់ដាស់ យ្ជុលុស សាច់ដាស់ និង យ្ជុលុស ។

ចំនួនរ៉ក់អ្ហាត់ក្នុងស្វ៉ឡាត់នីមួយៗមាន៖

១) ស្វ៉ឡាត់ ហ្វាច់រ៍ (الفجر) មាន ២ រ៉ក់អ្ហាត់ ។
២) ស្វ៉ឡាត់ ស្ហ៊ុស្វ៍ (الظهر) មាន ៤ រ៉ក់អ្ហាត់ ។
៣) ស្វ៉ឡាត់ អ្ហាស្វ៉រ៍ (العصر) មាន ៤ រ៉ក់អ្ហាត់ ។
៣) ស្វ៉ឡាត់ ម៉ាគ្រ៉ីប (المغرب) មាន ៣ រ៉ក់អ្ហាត់ ។
៤) ស្វ៉ឡាត់ អ៊ីស្ហាអ៊ុ (العشاء) មាន ៤ រ៉ក់អ្ហាត់ ។

មានពេលពិសេសក្នុងមួយថ្ងៃសម្រាប់បំពេញស្វ៉ឡាត់ទាំងនេះ ។

អល់ឡោះហ្វ៍មានព្រះបន្ទូលក្នុងគួរអានថា៖

*"ចូរអ្នកធ្វើនមស្ការពីពេលថ្ងៃជ្រេរហូតដល់ពេលងងឹតនៃពេលយប់ និង[ចូរអ្នក]សូត្រពេលមុនថ្ងៃរះ (ធ្វើនមស្ការបូជាអល់ឡោះហ្វ៍ពេលមុនថ្ងៃរះ សូត្រគួរអាន) ។ ព្រោះការសូត្រ (ធ្វើនមស្ការបូជាអល់ឡោះហ្វ៍ពេលមុនថ្ងៃរះ សូត្រគួរអាន) ពេលមុនថ្ងៃរះនោះមានបណ្តាសាក្សី (ទេវតា) ។" [១៧:៧៨]*

អាយ៉ាស់ខាងលើនេះបញ្ជាក់ឲ្យយើងដឹងថាពេលស្វ៍ឡាត់គឺៈ

- ពេលថ្ងៃជ្រេ - ពេលស្វ៍ឡាត់របស់ ស៊ុហ្វ៍រ៍ និង អាស្វ៍រ៍ (គឺពេលថ្ងៃចាប់ផ្ដើមជ្រេទៅទិសខាងលិច) ។
- ពេលងងឹតនៃពេលយប់ - ពេលស្វ៍ឡាត់របស់ ម៉ាក់រីប និង អ៊ីស្វ៉ាអ៍ (គឺពេលអស់ព័ណ៌ក្រហមពីទិសខាងកើត) ។
- សូត្រពេលមុនថ្ងៃរះ - ពេលស្វ៍ឡាត់របស់ ហ្វាច់រ៍ (គឺចាប់ផ្ដើមនៅចន្លោះពេលមានព័ណ៌សមែនទែន (គឺមិនមែនព័ណ៌សបញ្ឆោតទេ) និងពេលមុនថ្ងៃរះ) ។
- អធិប្បាយអំពីពេល គឺៈ

១) ស្វ៍ឡាត់ ហ្វាច់រ៍ - ចាប់ពីសេតារុន (ចាប់ពីពេលមានព័ណ៌សមុនពេលថ្ងៃរះ) រហូតដល់ថ្ងៃរះ ។

២) ស្វ៍ឡាត់ ស៊ុហ្វ៍រ៍ - ចាប់ពីពាក់កណ្ដាលថ្ងៃ (គឺរវាងថ្ងៃជ្រេនិងថ្ងៃលិច) រហូតដល់ពេលដែលអាចធ្វើស្វ៍ឡាត់ ៤ រ៉ក់អាត់បាន (គឺស្វ៍ឡាត់ អាស្វ៍រ៍) មុនថ្ងៃលិច ។

៣) ស្វ៍ឡាត់ អាស្វ៍រ៍ - ចាប់ពីពេលដែលអាចធ្វើស្វ៍ឡាត់ ៤ រ៉ក់អាត់បាន (គឺស្វ៍ឡាត់ ស៊ុហ្វ៍រ៍) ក្រោយពីពាក់កណ្ដាលថ្ងៃរហូតដល់ពេលថ្ងៃលិច ។

៤) ស្វ៍ឡាត់ ម៉ាក់រីប - ចាប់ពីពេលថ្ងៃលិច (គឺអស់ព័ណ៌ក្រហមពីទិសខាងកើត) រហូតដល់ពេលដែលអាចធ្វើស្វ៍ឡាត់ ៤ រ៉ក់អាត់បាន (គឺស្វ៍ឡាត់ អ៊ីស្វ៉ាអ៍) មុនពាក់កណ្ដាលយប់ (គឺរវាងថ្ងៃលិចនិងពេលថ្ងៃរះ) ។

៥) ស្វ៍ឡាត់ អ៊ីស្វ៉ាអ៍ - ចាប់ពីពេលដែលអាចធ្វើស្វ៍ឡាត់ ម៉ាក់រីប បាន (គឺ

ស្វ៊ូឡាត្ត៍ម៉ាក៉ុរីបទាន់ពេលកំណត់ភ្លាមៗ) រហូតដល់ពាក់កណ្ដាលយប់ ។

ទោះបីអល់ឡោះហ្វ៍បានប្រទានពេលទាំងនេះឲ្យយើងក៏ដោយ ក៏យើងត្រូវតែខិតខំធ្វើស្វ៊ូឡាត្ត៍ ភ្លាមៗកុំបណ្ដែតបណ្ដោយ ឲ្យទាន់ពេលដែលបានកំណត់នោះ (ពេលដែលល្អ) ព្រោះយើងមិនអាចរង់ចាំបានទេក្នុងការអរព្រះគុណអល់ឡោះហ្វ៍ ដោយសារតែព្រះអង្គទ្រង់សព្វព្រះហឫទ័យយើង និងដោយសារតែព្រះអង្គបានព្រះរាជទានអ្វីៗដែលល្អឲ្យយើង ។

# កិច្ចការសិស្ស ១៣

ចូរគូសពេលរបស់ស្ទីឡាត្ន់នីមួយៗនៅលើរង្វង់មូលនេះ។



**មេរៀនទី ១៤**

# សូត្រក្នុងស្ម៏ទ្បាត់

ដើម្បីចាប់ផ្តើមស្ម៏ទ្បាត់ អ្នកត្រូវឈរត្រៀមយ៉ាម ហើយនៀត គឺប៉ងក្នុងចិត្តថាអ្នកធ្វើអ្វីនិងដើម្បីអ្នកណា ។

នៀតគឺ៖ ខ្ញុំស្ម៏ទ្បាត់______________________________ _____រ៉ក់អ៊ាត់




ដើម្បីគាប់ព្រះហឫទ័យអល់ឡោះហ្វ ។

បន្ទាប់មក អ្នកត្រូវសូត្រតាក់ប៊ីរ៉ទុល អិះហ្ហ៍រ៉ម ថា៖




អល់ឡោះហ្វធំធ្ងើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

អ្នកត្រូវសូត្រស៊ូរ៉ោះត៍ អាល់-ហ្វាទីហ៊ាស់ និង ស៊ូរ៉ោះត៍មួយទៀត ក្នុងគួរអាន (ស៊ូរ៉ោះត៍ អាល់-អ៊ីខ្លាស្វ ជាដើម) ។

## ស៊ូរ៉ោះត៍ អាល់-ហ្វាទីហ៊ាស់

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

ដោយព្រះនាមអល់ឡោះហ្វ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។

ٱلۡحَمۡدُ لِلَّهِ رَبِّ ٱلۡعَٰلَمِينَ

សូមថ្វាយសេចក្តីសរសើរចំពោះអល់ឡោះហ្វ ម្ចាស់នៃពិភពទាំងពួង ។

ٱلرَّحۡمَٰنِ ٱلرَّحِيمِ

ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។

مَٰلِكِ يَوۡمِ ٱلدِّينِ

ព្រះម្ចាស់នៃថ្ងៃជំនុំជម្រះ

إِيَّاكَ نَعۡبُدُ وَإِيَّاكَ نَسۡتَعِينُ

ព្រះអង្គទេដែលអស់ទូលព្រះបង្គំជាខ្ញុំគោរពបូជា ព្រះអង្គទេដែលអស់ទូលព្រះបង្គំជាខ្ញុំអង្វរ សូមនូវជំនួយ ។

ٱهۡدِنَا ٱلصِّرَٰطَ ٱلۡمُسۡتَقِيمَ

សូមព្រះមេត្តាចង្អុលណែនាំអស់ទូលព្រះបង្គំជាខ្ញុំឆ្ពោះទៅកាន់មាគ៌ាត្រង់ត្រូវ ។

صِرَٰطَ ٱلَّذِينَ أَنۡعَمۡتَ عَلَيۡهِمۡ غَيۡرِ ٱلۡمَغۡضُوبِ عَلَيۡهِمۡ وَلَا ٱلضَّآلِّينَ

មាគ៌ារបស់បណ្តាអ្នកដែលព្រះអង្គបានព្រះរាជទានឲ្យនូវឧបការធម៌ ពុំមែន[មាគ៌ា]របស់បណ្តាអ្នកដែលទទួលរងនូវព្រះពិរោធទេ ហើយក៏ពុំមែន[មាគ៌ា]របស់បណ្តាអ្នកវង្វេងខុសទេដែរ ។

## ស៊ូរ៉ោះត៍ អាល់-អ៊ីខ្លាស្វ

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

ដោយព្រះនាមអល់ឡោះហ្ម៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។

قُلۡ هُوَ ٱللَّهُ أَحَدٌ

ចូរអ្នកថ្លែងថា៖ "ព្រះអង្គគឺអល់ឡោះហ្ម៍ ព្រះមួយគត់ ។

ٱللَّهُ ٱلصَّمَدُ

អល់ឡោះហ្ម៍ ព្រះអនន្តឥតទីបញ្ចប់ ។

لَمۡ يَلِدۡ وَلَمۡ يُولَدۡ

ព្រះអង្គមិនឲ្យកំណើតទេ ព្រះអង្គមិនត្រូវប្រសូតមកទេ ។

وَلَمۡ يَكُن لَّهُۥ كُفُوًا أَحَدُۢ

ពុំមានអ្វីប្រៀបប្រដូចព្រះអង្គឡើយ ។"



## កិច្ចការសិស្ស ១៤

ចូរសរសេរនៅក្រោមទង្វើ (រូប) នូវឥរិយាបថរបស់ត្ពុលិបនិងត្ពុលីបាស្ទុទាក់ទងនឹង៖

១) ភ្នែក

២) ដៃ

៣) ជើង



ចូរផាត់ព័ណ៌លើរូបត្ពុលិបនិងត្ពុលីបាស្ទុ ហើយចូរសិក្សាការស្ទូត្រឲ្យចាំ ។

**មេរៀនទី ១៥**

# សូត្រក្នុងស៊ូឡាត់

ពេលរុកុអ៍អ្នកត្រូវសូត្រថាៈ



سُبْحَانَ رَبِّيَ الْعَظِيْمِ وَ بِحَمْدِهِ



សូមថ្វាយសេចក្តីរុងរឿងចំពោះព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំ ព្រះដ៏ធំធេ្វីង សេចក្តីសរសើរទាំងអម្បាលម៉ានជារបស់ព្រះអង្គ ។

اللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَاٰلِ مُحَمَّدٍ

សូមអល់ឡោះហ្វ៍ព្រះរាជទានពរជ័យសិរីសួស្តីលើមូហ្ាំម៉ាដ្ ﷺ និងលើក្រុមគ្រួសារ عليهم السلام របស់មូហ្ាំម៉ាដ្ ﷺ ។

បន្ទាប់មក អ្នកងើបឡើងវិញ (គ៊ីយ៉ាម) រួចហើយសូត្រថាៈ



سَمِعَ اللّٰهُ لِمَنْ حَمِدَهِ

អល់ឡោះហ្វ៍ទ្រង់សវនាការអ្នកសរសើរព្រះអង្គ



اَللّٰهُ اَكْبَرُ

អល់ឡោះហ្ម៍ធំធ្វើងបំផុត ។

## កិច្ចការសិស្ស ១៥

ចូរសរសេរនៅក្រោមទង្វើ (រូប) នូវឥរិយាបថរបស់គ្រូលិបនិងគ្រូលីបាស្ទូទាក់ទងនឹង៖

១) ភ្នែក

២) ដៃ

៣) ជើង





ចូរផាត់ព័ណ៌លើរូបគ្រូលិបនិងគ្រូលីបាស្ទូ ហើយចូរសិក្សាការសូត្រឲ្យចាំ ។

**មេរៀនទី ១៦**

# សូត្រក្នុងស្វ៏ទ្បាត់

ពេលសាច់ដ្ហាស់អ្នកត្រូវសូត្រថា៖



سُبْحَانَ رَبِّيَ الْاَعْلٰى وَ بِحَمْدِهٖ



សូមថ្វាយសេចក្ដីរុងរឿងចំពោះព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំ ព្រះដ៏ខ្ពង់ខ្ពស់ សូមថ្វាយសេចក្ដីសរសើរទាំងអម្បាលម៉ានចំពោះព្រះអង្គ ។

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَاٰلِ مُحَمَّدٍ

សូមអល់ទ្បោះហ្វ៍ព្រះរាជទានពរជ័យសិរីសួស្ដីដល់មូហ្ាំម៉ាដ្ឋ ﷺ និងក្រុមគ្រួសារ عليهم السلام របស់មូហ្ាំម៉ាដ្ឋ ﷺ ។

បន្ទាប់មក អ្នកងើបមកអង្គុយ (យូ្លុស) រួចហើយសូត្រថា៖

اَللّٰهُ اَكْبَرُ



អល់ទ្បោះហ្វ៍ធំថ្កើងបំផុត ។



اَسْتَغْفِرُ اللّٰهَ رَبِّيْ وَ اَتُوْبُ اِلَيْهِ

ខ្ញុំស្វែងរកការអភ័យទោសពីអល់ទ្បោះហ្វ៍ ព្រះម្ចាស់ខ្ញុំ ហើយខ្ញុំត្រឡប់មករកព្រះអង្គវិញដោយដឹងកំហុសនិងរាងចាល ។

اَللّٰهُ اَكْبَرُ

អល់ទ្បោះហ្វ៍ធំថ្កើងបំផុត ។

បន្ទាប់មក អ្នកត្រូវស្វែយ្យដ្ធម្តងទៀត ។

## កិច្ចការសិស្ស ១៦

ចូរសរសេរនៅក្រោមទង្វើ (រូប) នូវឥរិយាបថរបស់ត៌្លិបនិងត៌្លីបាស្ទ់ទាក់ទងនឹង៖

១) ភ្នែក

២) ដៃ

៣) ជើង



ចូរផាត់ព័ណ៌លើរូបត៌្លិបនិងត៌្លីបាស្ទ់ ហើយចូរសូត្រឲ្យចាំ ។

**មេរៀនទី ១៧**

# សូត្រក្នុងស្ម៏ទ្បាត់

ពេលងើបឡើងវិញដើម្បីចាប់ផ្ដើមរ៉ក់អ៊ាស្ទ់បន្ទាប់ អ្នកត្រូវសូត្រថាៈ

بِحَوْلِ اللهِ وَ قُوَّتِهِ اَقُوْمُ وَ اَقْعُدُ

ខ្ញុំក្រោកឡើងនិងអង្គុយអាស្រ័យដោយកម្លាំងនិងឥទ្ធិពលរបស់អល់ឡោះហ្វ៍ ។

ក្នុងរ៉ក់អ៊ាស្ទ់ទី ២ ក្រោយពីសូត្រពេលគ្ញីយ៉ាម (គ្វីរ៉អាត់ قراءات) ស្វរ៉ោះត៏ អាល់-ហ្វាទីហ៊ាស្ទ់ និង អាល់-អ៊ីខ្លាស្វ៍ រួច អ្នកត្រូវសូត្រគ្នូនូត (قنوت) ។



ពេលគ្នូនូត អ្នកអាចឌូអ៊ាអ៍ (دعاء) ដូចតួយ៉ាងមួយនេះគឺៈ

رَبَّنَا اٰتِنَا فِيْ الدُّنْيَا حَسَنَةً وَّ فِيْ الْاٰخِرَةِ حَسَنَةً وَّقِنَا عَذَابَ النَّارِ

ឱព្រះជាម្ចាស់របស់អស់ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គព្រះរាជទានឲ្យអស់ទូលព្រះបង្គំជាខ្ញុំនូវសេចក្ដីល្អសម្រាប់លោកនេះនិងលោកមុខ ។

ក្នុងរ៉ក់អ៊ាស្ទ់ទី ៣ និងទី ៤ នៅពេលឈរគ្ញីយ៉ាម អ្នកត្រូវសូត្រ តាស់ប៊ីហ៊ាត់អារបាអ៊ាស្ទ់ (تسبيحات اربعه) ៣ ដង គឺៈ

سُبْحَانَ اللهِ وَ الْحَمْدُ لِلّٰهِ وَ لَا اِلٰهَ اِلَّا اللهُ وَ اللهُ اَكْبَرُ

សូមថ្វាយសេចក្តីសរសើរចំពោះអល់ឡោះហ្ញ៍ សូមថ្វាយសេចក្តីរុងរឿងចំពោះអល់ឡោះហ្ញ៍ មិនមានព្រះផ្សេងពីអល់ឡោះហ្ញ៍ឡើយ អល់ឡោះហ្ញ៍ទ្រង់ធំធ្វើងបំផុត ។

# កិច្ចការសិស្ស ១៧

ចូរសរសេរនៅក្រោមទង្វើ (រូប) នូវឥរិយាបថរបស់ត្ថ៍លិបនិងត្ថ៍លីបាស់ទាក់ទងនឹង៖

១) ភ្នែក

២) ដៃ

៣) ជើង



ចូរផាត់ព័ណ៌លើរូបត្ថ៍លិបនិងត្ថ៍លីបាស់ ហើយចូរសិក្សាការសូត្រឲ្យចាំ ។

**មេរៀនទី ១៨**

# សូត្រក្នុងស៊ូឡាត់

បន្ទាប់ពីសាច់ដ្ធាស់ទី ២ ក្នុងរ៉ក់អាត់ទី ២ អ្នកត្រូវសូត្រះ

១) តាស្ហាស់ហ៊ូដ្ធ (تشهد) បើស៊ូឡាត់ ៣ ឬ ៤ រ៉ក់អាត់ ។
២) តាស្ហាស់ហ៊ូដ្ធ (تشهد) និង សាឡាម បើស៊ូឡាត់ ២ រ៉ក់អាត់ ។

**តាស្ហាស់ហ៊ូដ**

اَشْهَدُ اَنْ لَا اِلٰهَ اِلَّا اللّٰهُ وَحْدَهُ لَا شَرِيْكَ لَهُ

ខ្ញុំប្តេជ្ញាថាពុំមានព្រះផ្សេងពីអល់ឡោះហ្ន៍ឡើយ ព្រះអង្គឯកឯង ពុំមានសហការីឡើយ

وَ اَشْهَدُ اَنَّ مُحَمَّدًا عَبْدُهُ وَ رَسُوْلُهُ

ខ្ញុំសូមប្តេជ្ញាថាមូហាំម៉ាដ់ជាបាវបម្រើរបស់ព្រះអង្គ និងជា សាស្តារបស់ព្រះអង្គ ។

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَّ اٰلِ مُحَمَّدٍ

ឱអល់ឡោះហ្ន៍ សូមព្រះអង្គព្រះរាជទានពរជ័យសិរីសួស្តីមកដល់មូហាំម៉ាដ់និងក្រុមគ្រួសាររបស់មូហាំម៉ាដ់ ។





**សាឡាម**

اَلسَّلَامُ عَلَيْكَ اَيُّهَا النَّبِيُّ وَ رَحْمَةُ اللهِ وَ بَرَكَاتُهُ

សូមឲ្យសិរីសួស្តី (របស់អល់ឡោះហ្វ៍) កើតមានដល់ព្រះអង្គទាំងឡាយ ឱបណ្តាសាស្តាអើយ ព្រមទាំងព្រះមេត្តាធម៌របស់អល់ឡោះហ្វ៍និងពរជ័យរបស់ព្រះអង្គ ។

اَلسَّلَامُ عَلَيْنَا وَ عَلٰى عِبَادِ اللهِ الصَّالِحِيْنَ

សូមឲ្យសិរីសួស្តីកើតមានដល់យើង និងដល់បណ្តាបាវបម្រើមានសទ្ធារបស់អល់ឡោះហ្វ៍

اَلسَّلَامُ عَلَيْكُمْ وَ رَحْمَةُ اللهِ وَ بَرَكَاتُهُ

សូមឲ្យសិរីសួស្តី កើតមានដល់ព្រះអង្គទាំងឡាយ (មូហ្ហាំម៉ាដ្ធ៍និងព្រះរាជកុលដ្ឋានព្រះអង្គ និងបណ្តាសាស្តានិងទេវតា) ព្រមទាំងព្រះមេត្តាធម៌របស់អល់ឡោះហ្វ៍និងពរជ័យរបស់ព្រះអង្គ ។

បន្ទាប់មក សូត្រ ៣ ដង ព្រមទាំងលើកដៃរាល់ដង ថាៈ

اَللهُ اَكْبَرُ

អល់ឡោះហ្វ៍ធំថ្កើងបំផុត ។

បន្ទាប់មកទៀត សូត្រ ៣ ដង ថាៈ

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَّ اٰلِ مُحَمَّدٍ

ឱអល់ឡោះហ្វ៍ សូមព្រះអង្គព្រះរាជទានពរជ័យសិរីសួស្តីមកដល់មូហ្ហាំម៉ាដ្ធ៍និងក្រុមគ្រួសាររបស់មូហ្ហាំម៉ាដ្ធ៍ ។





# កិច្ចការសិស្ស ១៨

ចូរសរសេរនៅក្រោមទង្វើ (រូប) នូវឥរិយាបថរបស់ត្ឋ៏លិបនិង ត្ឋ៏លីបាស្ហ់ទាក់ទងនឹង៖

១) ភ្នែក

២) ដៃ

៣) ជើង

តើសាឡាមទាំង ៣ ឲ្យទៅលើអ្នកណាខ្លះ ?



ចូរផាត់ព័ណ៌លើរូបត្ឋ៏លិបនិងត្ឋ៏លីបាស្ហ់ ហើយចូរសូត្រឲ្យចាំ ។

**មេរៀនទី ១៩**

# សាឡើងវិញ - សូត្រក្នុងស្វឺឡាត់

១) **គ្ញីយ៉ាម**

ខ្ញុំធ្វើស្វឺឡាត់_______________________________ _____រ៉ក់អាត់

قُرْبَةً اِلَى اللّٰهِ

ដើម្បីគាប់ព្រះហឫទ័យអល់ឡោះហ្ ។

اَللّٰهُ اَكْبَرُ

អល់ឡោះហ្ធំធ្វើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

សូត្រស៊ូរ៉ោះត៍ អាល់-ហ្វាទីហ៊ាស់ និង ស៊ូរ៉ោះត៍គួរអានមួយទៀត

២) **រូគុអ៍**

سُبْحَانَ رَبِّيَ الْعَظِيْمِ وَ بِحَمْدِهِ

សូមថ្វាយសេចក្ដីរុងរឿងចំពោះព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំ ព្រះដ៏ធំធ្វើង សូមថ្វាយសេចក្ដីសរសើរទាំងអម្បាលម៉ានចំពោះព្រះអង្គ ។

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَآلِ مُحَمَّدٍ

សូមអល់ឡោះហ្វព្រះរាជទានពរជ័យសិរីសួស្ដីដល់មូហាំម៉ាដ់ﷺ និងដល់ក្រុមគ្រួសារعليهم السلامរបស់មូហាំម៉ាដ់ﷺ ។

៣) **គ្ញីយ៉ាម**

سَمِعَ اللّٰهُ لِمَنْ حَمِدَهٖ

អល់ឡោះហ្វ៍ទ្រង់សវនាការអ្នកសរសើរព្រះអង្គ

اَللّٰهُ اَكْبَرُ

អល់ឡោះហ្វ៍ធំថ្កើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

៤) **សាច់្ជដាស់**

سُبْحَانَ رَبِّيَ الْاَعْلٰى وَ بِحَمْدِهٖ

សូមថ្វាយសេចក្តីរុងរឿងចំពោះព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំ ព្រះដ៏ខ្ពង់ខ្ពស់ សូមថ្វាយសេចក្តីសរសើរទាំងអម្បាលម៉ានចំពោះព្រះអង្គ ។

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَاٰلِ مُحَمَّدٍ

សូមអល់ឡោះហ្វ៍ព្រះរាជទានពរជ័យសិរីសួស្តីដល់មូហ្ាំម៉ាដ្ជ់ صلى الله عليه وآله وسلم និងដល់ក្រុមគ្រួសារ عليهم السلام របស់មូហ្ាំម៉ាដ្ជ់ صلى الله عليه وآله وسلم ។

៥) **យ្ជូលុស**

اَللّٰهُ اَكْبَرُ

អល់ឡោះហ្វ៍ធំថ្កើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

اَسْتَغْفِرُ اللّٰهَ رَبِّيْ وَ اَتُوْبُ اِلَيْهِ

ខ្ញុំស្វែងរកការអភ័យទោសពីអល់ឡោះហ្វ៍ ព្រះម្ចាស់ខ្ញុំ ហើយខ្ញុំត្រឡប់មករកព្រះអង្គវិញដោយដឹងកំហុសនិងរាងចាល ។

اَللّٰهُ اَكْبَرُ

អល់ឡោះហ្វ៍ធំថ្កើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

៦) **សាច់ដ្ញាស់**

سُبْحَانَ رَبِّيَ الْاَعْلٰى وَ بِحَمْدِهِ

សូមថ្វាយសេចក្ដីរុងរឿងចំពោះព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំ ព្រះដ៏ខ្ពង់ខ្ពស់ សូមថ្វាយសេចក្ដីសរសើរទាំងអម្បាលម៉ានចំពោះព្រះអង្គ ។

اللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَاٰلِ مُحَمَّدٍ

សូមអល់ឡោះហ្វ៍ព្រះរាជទានពរជ័យសិរីសួស្ដីដល់មូហាំម៉ាដ្ ﷺ និងដល់ក្រុមគ្រួសារ عليهم السلام របស់មូហាំម៉ាដ្ ﷺ ។

៧) **យ៉ួលុស**

اَللّٰهُ اَكْبَرُ

អល់ឡោះហ្វ៍ធំធ្ងើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

៨) ពេលងើបឡើងវិញដើម្បីចាប់ផ្ដើមរ៉ក់អ្ញាត់បន្ទាប់៖

بِحَوْلِ اللّٰهِ وَ قُوَّتِهِ اَقُوْمُ وَ اَقْعُدُ

ខ្ញុំក្រោកឡើងនិងអង្គុយអាស្រ័យដោយកម្លាំងនិងឥទ្ធិពលរបស់អល់ឡោះហ្វ៍ ។

៩) ក្នុងរ៉ក់អ្ញាត់ទី ២ ពេលឈរគ្វីយ៉ាម (គ្វីរ៉អាត់ قرآت) សូត្រស្ហ៊ូរ៉ោះត៍ អាល់-ហ្វាទីហ៊ាស់ និង អាល់-អ៊ីខ្លាស់ ។

១០) **គ្នូត**

رَبَّنَا اٰتِنَا فِيْ الدُّنْيَا حَسَنَةً وَّ فِيْ الْاٰخِرَةِ حَسَنَةً وَّ قِنَا عَذَابَ النَّارِ

ឱព្រះជាម្ចាស់របស់អស់ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គព្រះរាជទានឲ្យអស់ទូលព្រះបង្គំជាខ្ញុំនូវសេចក្ដីល្អសម្រាប់លោកនេះនិងលោកមុខ ហើយសូមព្រះអង្គ

ឲ្យអស់ទូលព្រះបង្គំជាខ្ញុំបានរួចផុតពីភ្លើងនរកផង ។

១១)

**រូគុអ៍, គ្ទីយ៉ាម**
**សាច់ដ្វាស់, យ៉ូលុស** } ដូចរ៉ក់អ៊ាត់ទី ១
**សាច់ដ្វាស់, យ៉ូលុស**

១២) ពេលអង្គុយយ៉ូលុស៖

-តាស្ហាស់ហ្វ៊ូដ បើស្ម៏ឡាត់ ៣ ឬ ៤ រ៉ក់អ៊ាត់ ។

-តាស្ហាស់ហ្វ៊ូដ និង សាឡាម បើស្ម៏ឡាត់ ២ រ៉ក់អ៊ាត់ ។

**តាស្ហាស់ហ្វ៊ូដ**

اَشْهَدُ اَنْ لَا اِلٰهَ اِلَّا اللّٰهُ وَحْدَهُ لَا شَرِيْكَ لَهُ

ខ្ញុំប្ដេជ្ញាថាពុំមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ ព្រះអង្គឯកឯង ពុំមានសហាការីឡើយ

وَ اَشْهَدُ اَنَّ مُحَمَّدًا عَبْدُهُ وَ رَسُوْلُهُ

ខ្ញុំសូមប្ដេជ្ញាថាមូហ្ហាំម៉ាដ់ជាបាវបម្រើរបស់ព្រះអង្គ និងជាសាស្ដារបស់ព្រះអង្គ ។

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَّ اٰلِ مُحَمَّدٍ

សូមអល់ឡោះហ្វ៍ព្រះរាជទានពរជ័យសិរីសួស្ដីដល់មូហ្ហាំម៉ាដ់ﷺ និងដល់ក្រុមគ្រួសារعليهم السلامរបស់មូហ្ហាំម៉ាដ់ﷺ ។

**សាឡាម**

اَلسَّلَامُ عَلَيْكَ اَيُّهَا النَّبِيُّ وَ رَحْمَةُ اللهِ وَ بَرَكَاتُهُ

សូមឲ្យសិរីសួស្តី (របស់អល់ឡោះហ្) កើតមានដល់ព្រះអង្គទាំងឡាយ ឱបណ្ដាសាស្ដាអឺយ ព្រមទាំងព្រះមេត្តាធម៌របស់អល់ឡោះហ្ និងពរជ័យរបស់ព្រះអង្គ ។

اَلسَّلَامُ عَلَيْنَا وَ عَلٰى عِبَادِ اللهِ الصَّالِحِيْنَ

សូមឲ្យសិរីសួស្តីកើតមានដល់យើង និងដល់បណ្ដាបាវបម្រើមានសទ្ធារបស់អល់ឡោះហ្ ។

اَلسَّلَامُ عَلَيْكُمْ وَ رَحْمَةُ اللهِ وَ بَرَكَاتُهُ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គទាំងឡាយ (មូហាំម៉ាដ់និងព្រះរាជកុលដ្ឋានព្រះអង្គ និងបណ្ដាសាស្ដានិងទេវតា) ព្រមទាំងព្រះមេត្តាធម៌របស់អល់ឡោះហ្និងពរជ័យរបស់ព្រះអង្គ ។

បន្ទាប់មក សូត្រ ៣ ដង ព្រមទាំងលើកដៃរាល់ដង ថា៖

اَللّٰهُ اَكْبَرُ

អល់ឡោះហ្ធំធ្កើងបំផុត ។

បន្ទាប់មកទៀត សូត្រ ៣ ដង ថា៖

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَّ اٰلِ مُحَمَّدٍ

សូមអល់ឡោះហ្ព្រះរាជទានពរជ័យសិរីសួស្តីដល់មូហាំម៉ាដ់ﷺ និងដល់កុមគ្រួសារعليهم السلامរបស់មូហាំម៉ាដ់ﷺ ។

១៣) ក្នុងរ៉ក់អាត់ទី ៣ និងទី ៤ នៅពេលឈរត្បីយ៉ាម អ្នកត្រូវសូត្រតាស់ប៊ីហ្វាត់ អារបាអាស់ (تسبيحات اربعه) ៣ ដង គឺ៖

سُبْحَانَ اللهِ وَ الْحَمْدُ لِلّٰهِ وَ لَا اِلٰهَ اِلَّا اللهُ وَ اللهُ اَكْبَرُ

សូមថ្វាយសេចក្ដីសរសើរចំពោះអល់ឡោះហ្ សូមថ្វាយសេចក្ដីរុងរឿងចំពោះអល់ឡោះហ្ មិនមានព្រះផ្សេងពីអល់ឡោះហ្ឡើយ អល់ឡោះហ្ទ្រង់ធំធ្កើង

បំផុត ។

# កាយវិការក្នុងស្ម៏ទ្បាត់



តាក់បីរ៉ទុល អិះហ្ប៉ារ៉ម គ្ទីយ៉ាម រូគុអ៊ុ គ្ទីយ៉ាម សាច់ដ្វាស់ យូ្លុស សាច់ដ្វាស យូ្លុស



គ្ទីយ៉ាម គូ្នូត រូគុអ៊ុ គ្ទីយ៉ាម សាច់ដ្វាស់ យូ្លុស សាច់ដ្វាស់



យូ្លុស (ចប់)



តាក់បីរ៉ទុល អិះហ្ប៉ារ៉ម គ្ទីយ៉ាម រូគុអ៊ុ គ្ទីយ៉ាម សាច់ដ្វាស់ យូ្លុស សាច់ដ្វាស់



ឃ្ជុលុស គ្ហីយ៉ាម គ្ហុនូត រុគុអ៊៍ គ្ហីយ៉ាម សាច់ដ្ជាស់ ឃ្ជុលុស



សាច់ដ្ជាស ឃ្ជុលុស (ចប់)

កំណែលើកទី ២, 06/2020